00398378

E176

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**អង្គជំនុំជម្រះសាលាដំបូង**

Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អវតក/អជសដ
Case File/ Dossier N° 001/18-07-2007-ECCC/TC

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 28 / 10 / 2009
ម៉ោង (Time/Heure) : 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: C.A.Fuy

| | |
|---|---|
| ចំពោះមុខ | ចៅក្រម **និល ណុន** ប្រធាន |
| | ចៅក្រម **Silvia CARTWRIGHT** |
| | ចៅក្រម **យ៉ា សុខន** |
| | ចៅក្រម **Jean-Marc LAVERGNE** |
| | ចៅក្រម **ធូ មណី** |
| កាលបរិច្ឆេទ | ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៩ |
| ចំណាត់ថ្នាក់ឯកសារ | សាធារណៈ |

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date /Date de certification): 29 / 10 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: C.A.Fuy

## សេចក្តីសម្រេចលើសំណើរបស់ភាគីនានាសុំដាក់សម្ភារៈមួយចំនួន នៅចំពោះមុខអង្គជំនុំជម្រះ អនុលោមតាមវិធានផ្ទៃក្នុង ៨៧(២)

**<u>សហព្រះរាជអាជ្ញា</u>**
ជា លាង
William SMITH (ស្តីទី)
**<u>មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**

**<u>ជនជាប់ចោទ</u>**
កាំង ហ្គេកអ៊ាវ ហៅ ឌុច
**<u>មេធាវីជនជាប់ចោទ</u>**

អង្គជំនុំជម្រះសាលាដំបូង TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C B T C

ផ្លូវជាតិលេខ ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុងភ្នំពេញ កម្ពុជា ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ: (៨៥៥)-២៣-២១៨-៩១៤ ទូរសារ: (៨៥៥)-២៣-២១៨-៩៤១ គេហទំព័រ: www.eccc.gov.kh
National Road 4, Chaom Chau, Dangkao, Phnom Penh. Mail Po Box 71, Tel:+855(0)23 218914 Fax:023 218941
Web: www.eccc.gov.kh

E176

គង់ ពិសី
ហុង គឹមសួន
យុង ផានិត
គឹម ម៉េងឃី
ម៉ុច សុវណ្ណារី
Silke STUDZINSKY
Martine JACQUIN
Philippe CANONNE

ទី ស្រីនណា
Piere Olivier SUR
Alain WERNER
Brianne McGONIGLE
Annie DELAHAIE
Elizabeth RABESANDRATANA
Karim KHAN
Fabienne TRUSSES-NAPROUS
Christine MARTINEAU

ការ សាវុត្ថ
François ROUX
Marie-Paule CANIZARÈS

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C E T C

E176

# I. សេចក្តីផ្តើម

១. កាលពីថ្ងៃទី១៦ និងទី១៧ ខែកញ្ញា ឆ្នាំ២០០៩ យោងតាមការអញ្ជើញរបស់អង្គជំនុំជម្រះ ភាគី នានាបានធ្វើសំណើផ្ទាល់មាត់មួយចំនួន ដើម្បីសុំដាក់សម្ភារៈផ្សេងៗគ្នានៅចំពោះមុខអង្គជំនុំជម្រះ អនុលោមតាមវិធាន ៨៧(២) នៃវិធានផ្ទៃក្នុង[១]។ អង្គជំនុំជម្រះកត់សម្គាល់ឃើញជាដំបូងថា សំណើផ្សេងៗគ្នាអាចយកមកជជែកពិភាក្សាបាន នៅពេលដែលសម្ភារៈនោះត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះរួចហើយ ហើយដែលសម្ភារៈនោះត្រូវឆ្លងកាត់ ការដេញដោល[២]។ សំណើមួយចំនួនទៀតសុំដាក់សម្ភារៈបន្ថែមនៅចំពោះមុខអង្គជំនុំជម្រះ ឬសេចក្តី

[១] ប្រតិចារឹក ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៩ ទំព័រ៥៣-១១៥; ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៩ ទំព័រ១-៤៧។ សំណើមួយចំនួនត្រូវបានភ្ជាប់នៅក្នុងពាក្យសុំកាលពីលើកមុន ដែលត្រូវបានដាក់ដោយភាគីទាំងឡាយ។ នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៩ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ បានស្វះស្វែងចុះឯកសារ និងបានដាក់ជាបន្តបន្ទាប់នៅមុខអង្គជំនុំជម្រះ នូវភស្តុតាងថ្មី (គឺបញ្ជីឈ្មោះជាក់លាក់នៃអ្នកទោស ស-២១) ក្រោមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង។ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនចុះថ្ងៃទី៦ ខែតុលា ឆ្នាំ២០០៩ អង្គជំនុំជម្រះបានបដិសេធសំណើនេះ។ (សូមមើល "សេចក្តីសម្រេចលើសំណើសុំផ្ទាល់មាត់របស់មេធាវីដើមបណ្តឹងរដ្ឋបវេណីក្រុម១ ស្នើសុំការអនុញ្ញាតដាក់ឯកសារថ្មី" ចុះថ្ងៃទី៦ ខែតុលា ឆ្នាំ២០០៩ (ឯកសារ E173))។ នៅខណៈដែលមេធាវីការពារក្តីបានស្នើសុំយ៉ាងសំខាន់ថា បទសម្ភាសន៍មួយដែលបានផ្តល់ដោយដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី ឲ្យសារព័ត៌មានបារាំង ត្រូវដាក់នៅមុខអង្គជំនុំជម្រះផងដែរ សំណើនេះត្រូវបានដកជាផ្លូវការបន្តបន្ទាប់។

[២] សំណើទាំងនេះជាប់ទាក់ទងនឹងឯកសារ 5.1 ពីសេចក្តីសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ("លិខិតមន្ទីរស-២១ ពី ឌុច ផ្ញើជូន យ៉ា") (ឯកសារ E3/372) និង "លិខិតមន្ទីរស-២១ ពី ប៊ុន ផ្ញើជូន យ៉ា") (ឯកសារ E3/377), ត្រូវបានស្នើសុំដោយដើមបណ្តឹងរដ្ឋប្បវេណីក្រុម១។ ឯកសារ D80/2 (សំឡេងពីមន្ទីរស-២១ -- ភាពព្រឺខ្លាច និងប្រវត្តិក្នុងគុកសម្ងាត់របស់ ប៉ុល ពត") ដោយ David Chandler, បោះពុម្ពដោយ Silkworm Books (ឯកសារ E3/427)។ ឯកសារ D80/4 ("Le Portail", ដោយ François Bizot, បោះពុម្ពដោយ Folio, ២000 (ឯកសារ E3/4)។ ឯកសារ D80/5 ("Les clés du Cambodge"), ដោយ Raoul Marc Jennar, បោះពុម្ពដោយ Maisoneuve et Larose, ១៩៩៥ (ឯកសារ E3/515)). ឯកសារ D80/8 ("Genocide sites in Cambodia (1975-1979), កម្មវិធីអំពើប្រល័យពូជសាសន៍កម្ពុជា, សកលវិទ្យាល័យ Yale (ឯកសារ E3/512))។ ឯកសារ D80/9 ("Composite Landsat Satellite images of Cambodia, 1972-1976, និង ១៩៨០ ដោយមានរណ្តៅសាកសពរួម និងកន្លែងឃុំឃាំងពីឆ្នាំ១៩៧៥-១៩៧៩"), កម្មវិធីអំពើប្រល័យពូជសាសន៍កម្ពុជា, សកលវិទ្យាល័យ Yale (ឯកសារ E3/513))។ ឯកសារ D80/10 ("Mapping the Killing fields of Cambodia 1975-1979", មជ្ឈមណ្ឌលឯកសារកម្ពុជា (ឯកសារ E3/514)) និង ឯកសារ D82 ("លិខិតរបស់មេធាវី ឌុច ស្តីពីការដាក់តម្កល់សេចក្តីពិគ្រោះយោបល់ដែលបានរៀបចំធ្វើដោយលោក Raoul M. Jennar នៅក្នុងសំណុំរឿងស៊ើបសួរ" (ឯកសារ E3/511))។ សំណើក្រោយមកទៀតត្រូវបានធ្វើឡើងដោយមេធាវីការពារក្តី។



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C E T C

00398381

E176

បំភ្លឺអំពីលក្ខណៈនៃឯកសារមួយចំនួន ដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះកាលពីលើកមុន។

## II. សំអាងហេតុ

### ក. ក្របខណ្ឌច្បាប់

២. វិធាន ៨៧(២) នៃវិធានផ្ទៃក្នុង ចែងថា "សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះត្រូវផ្អែកតែលើភស្តុតាងដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះតែប៉ុណ្ណោះ ហើយដែលភស្តុតាងនោះត្រូវឆ្លងកាត់ការជជែកដេញដោល"។ ទោះបីជាអត្ថន័យនៃវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុងសំដៅលើ "ភស្តុតាង ដែលមាននៅក្នុងសំណុំរឿង" ក៏ដោយ ក៏ជាក់ស្ដែងនៅក្នុងវិធាន ៨៧ ទាំងមូលបង្ហាញច្បាស់ថា សម្ភារៈនៅក្នុងសំណុំរឿងមិនមែនជា "ភស្តុតាង" ទេ រហូតទាល់តែសម្ភារៈនោះត្រូវបានដាក់នៅចំពោះមុខតុលាការស្របតាមវិធាន ៨៧(២) នៃវិធានផ្ទៃក្នុង[៣]។ យោងតាម វិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង សម្ភារៈដែលមាននៅក្នុងសំណុំរឿងត្រូវបានចាត់ទុកថា បានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះ ប្រសិនបើខ្លឹមសាររបស់វាត្រូវបានសង្ខេប ឬ ត្រូវបានអាននៅក្នុងសវនាការ ឬត្រូវបានកំណត់បង្ហាញអត្តសញ្ញាណយ៉ាងសមស្រប[៤]។ សម្ភារៈអាចត្រូវបានចាត់ទុកថា ត្រូវឆ្លងកាត់ការជជែកដេញដោល នៅពេលដែលត្រូវបានផ្ដល់ឱកាសឲ្យលើកទឡ្ហីករណ៍តទល់គ្នា ទោះបីជានៅពេលដែលភាគីនានាមិនប្រើប្រាស់ឱកាសនេះក៏ដោយ។

៣. នៅពេលដាក់ឯកសារនៅចំពោះមុខអង្គជំនុំជម្រះ ភាគីត្រូវគូសបញ្ជាក់ថា តើខ្លួនស្នើសុំឲ្យមានការពិចារណាទៅលើឯកសារនោះទាំងមូលដែរឬទេ។ ក្នុងករណីដែលភាគីស្នើសុំដាក់តែ

---

[៣] "សេចក្ដីសម្រេចស្ដីពីភាពអាចទទួលយកសម្ភារៈដែលមាននៅក្នុងសំណុំរឿងធ្វើជាភស្តុតាង" ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៩ (ឯកសារ E43/4) កថាខណ្ឌ៦។

[៤] បញ្ហានេះក៏ត្រូវបានឆ្លុះបញ្ចាំងក្នុងការអនុវត្តរបស់អង្គជំនុំជម្រះមុនការអនុម័តយកវិធាន៨៧(៣)បច្ចុប្បន្ន នៃវិធានផ្ទៃក្នុង (*សូមមើល ជាឧទាហរណ៍* ប្រតិចារឹក ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ៨៣-៨៤)។



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C E T C

ផ្នែកខ្លះនៃឯកសារនោះ ភាគីនោះគួរតែកំណត់អំពីផ្នែកដែលពាក់ព័ន្ធនោះ[៥]។ វិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង បានចែងថែមទៀតថា ដើម្បីបង្កើតបានជាភស្តុតាង សម្ភារៈត្រូវបំពេញឱ្យបាននូវបទដ្ឋានអប្បរមាដូចជាភាពជាប់ពាក់ព័ន្ធ និងភាពអាចជឿជាក់បាន[៦]។ នៅពេលដាក់នៅចំពោះមុខអង្គជំនុំជម្រះ អង្គជំនុំជម្រះត្រូវធ្វើការវាយតម្លៃអំពីតម្លៃជាភស្តុតាងនៃភស្តុតាងទាំងអស់នោះ និងថ្លឹងថ្លែងសម្រេចដើម្បីឱ្យស្របជាមួយនឹងការវាយតម្លៃនោះ[៧]។

៤. នៅពេលដែលភាគីនានាស្នើសុំឱ្យទទួលយកនូវភស្តុតាងថ្មីស្របតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ភាគីដែលស្នើសុំ ត្រូវបង្ហាញថា សក្ខីកម្មឬភស្តុតាងដែលបានស្នើសុំមិនអាចរកបាននៅមុនពេលចាប់ផ្តើមជំនុំជម្រះទេ[៨]។ បន្ថែមពីលើការបំពេញលក្ខខណ្ឌវិនិច្ឆ័យនៃភាពជាប់ពាក់ព័ន្ធ និងភាពអាចជឿជាក់បាននៅក្នុងវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះត្រូវធ្វើការសម្រេចថា តើសម្ភារៈនេះបានបំពេញនូវលក្ខខណ្ឌដែលបានកំណត់ នៅក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុងដែរឬទេ។

## ខ. សម្ភារៈដែលបានស្នើសុំដោយការិយាល័យសហព្រះរាជអាជ្ញា

៥. ឯកសារ D99/1 គឺជាផែនទីមន្ទីរសន្តិសុខ ស-២១ ដែលថតពីលើអាកាសដែលបានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហេតុនេះហើយវាជាផ្នែកមួយនៃសំណុំរឿង[៩]។ មេធាវីការពារក្តីមិនបានតវ៉ាថា ឯកសារនេះគឺមិនមែនជាភស្តុតាងនោះទេ។

---

[៥] ប្រតិចារឹកចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៩ ទំព័រ៤-៥។

[៦] វិធាន៨៧(៣) នៃវិធានផ្ទៃក្នុង ចែងថា អង្គជំនុំជម្រះសាលាដំបូងអាចបដិសេធចំពោះពាក្យសុំឱ្យពិនិត្យភស្តុតាង បើយល់ឃើញថា ៖ ក-មិនជាប់ពាក់ព័ន្ធ ឬ ជាការស្នើសុំជាន់គ្នា ខ-មិនអាចរកបានក្នុងរយៈពេលសមស្របណាមួយ។ គ-មិនសមស្របសំរាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្តុតាង ។ ឃ-ច្បាប់មិនអនុញ្ញាត ឬ ង-មានចេតនាពន្យាកិច្ចដំណើរការនីតិវិធី ឬគ្មានប្រយោជន៍។

[៧] “សេចក្តីសម្រេចស្តីពីភាពអាចទទួលយកសម្ភារៈដែលមាននៅក្នុងសំណុំរឿងធ្វើជាភស្តុតាង” ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៩ (ឯកសារ E43/4) កថាខណ្ឌ៥-៧។

[៨] “សេចក្តីសម្រេចពីភាពអាចទទួលយកបាននៃភស្តុតាងថ្មី និងសេចក្តីណែនាំដល់ភាគីទាំងអស់” ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩ (ឯកសារ E5/10/2) កថាខណ្ឌ៥។

[៩] “ឧបសម្ព័ន្ធ ក៖ ផែនទីមន្ទីរសន្តិសុខ ស-២១” (ឯកសារ D99/1)។



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C E T C

អង្គជំនុំជម្រះ រកឃើញថា ឯកសារនេះមានជាប់ពាក់ព័ន្ធនឹងការកាត់សេចក្តី និងយល់ព្រម តាមសំណើសុំ របស់សហព្រះរាជអាជ្ញា។

៦. ឯកសារ E61.1 ជាតារាង ផ្ទុកនូវឯកសារយោងលើសម្ភារៈចំនួន ៤៣០ នៅក្នុងសំណុំរឿង យោងតាមសហព្រះរាជអាជ្ញា សម្ភារៈទាំងអស់នេះពាក់ព័ន្ធនឹងអត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិរវាងប្រទេសកម្ពុជានិងប្រទេសវៀតណាម នៅក្នុងអំឡុងពេលដែលពាក់ព័ន្ធទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ("សម្ភារៈជម្លោះប្រដាប់អាវុធ")[១០]។ សម្ភារៈមួយចំនួនក្នុងចំណោមសម្ភារៈទាំងអស់នេះ ឬផ្នែកខ្លះនៃសម្ភារៈទាំងនេះ ត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះរួចហើយ និងត្រូវបានយោងនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការផងដែរ។ បន្ថែមពីលើសំណើសុំរបស់មេធាវីការពារក្តីថ្មីៗនេះ សហព្រះរាជអាជ្ញាបានដាក់សេចក្តីសង្ខេបអំពីសម្ភារៈទាំងអស់នេះ[១១]។ ចំណែកមេធាវីការពារក្តីកត់សម្គាល់អំពីសេចក្តីសង្ខេបនេះថា វាមិនឆ្លុះបញ្ចាំងទាំងស្រុងអំពីខ្លឹមសារនៃសម្ភារៈទាំងអស់ដែលស្នើសុំដាក់នោះទេ។ មេធាវីការពារក្តីមិនជំទាស់ទៅនឹងការប្រើប្រាស់សម្ភារៈទាំងអស់នេះធ្វើជាភស្តុតាងនោះទេ ដោយមានអញ្ញត្រកម្មលើឯកសារចំនួនប្រាំបួនដែលបានរៀបរាប់ថាជាចម្លើយរបស់ជនជាប់សង្ស័យ[១២]។ ឯកសារទាំងអស់នេះរួមមាន ទូរលេខដែលបានផ្ញើទៅក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ក៏ដូចជាការផ្សព្វផ្សាយព័ត៌មានដែលមានលក្ខណៈជាសេចក្តីដកស្រង់សន្ទរកថា ដែលបានកំណត់ថាជារបស់បុគ្គលនានាដែលបច្ចុប្បន្ននេះត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង លេខ០០២ ។ ទោះបីជាមាន

---

[១០] "ឧបសម្ព័ន្ធ ក៖ ជម្លោះប្រដាប់អាវុធ" ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៩ (ឯកសារ E61.1)។ សូមមើលផងដែរ "សេចក្តីសន្និដ្ឋានស្របតាម វិធាន៩២៖ សេចក្តីជូនដំណឹងស្តីពីឯកសារទាក់ទងនឹងជម្លោះប្រដាប់អាវុធដែលត្រូវដាក់ជូនអង្គជំនុំជម្រះសាលាដំបូង អនុលោមតាមវិធាន ៨៧.២ នៃវិធានផ្ទៃក្នុង" ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៩ (ឯកសារ E61)។

[១១] "សេចក្តីសង្ខេបនៃឯកសារទាំងឡាយដែល សហព្រះរាជអាជ្ញា បានដាក់ដើម្បីបង្ហាញសក្ខីកម្មអំពីអត្ថិភាពនៃជម្លោះប្រដាប់អាវុធ ដែលបានដាក់ជាមួយញត្តិរបស់ពួកគេនៃថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៩ -- ឧបសម្ព័ន្ធ ក", ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០៩ (ឯកសារ E61/1.1)។

[១២] "សេចក្តីកត់សម្គាល់របស់ក្រុមមេធាវីការពារក្តី លើសេចក្តីសង្ខេបរបស់សហព្រះរាជអាជ្ញា ទាក់ទិននឹងឯក[illegible] ស្តីពីជម្លោះប្រដាប់អាវុធ និងលើសំណើរបស់ក្រុមការពារក្តីទាក់ទងនឹងសេចក្តីប្រកាសរបស់ជនត្រូវ[illegible] សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អ.វ.ត.ក-ក.ស.ច.ស" ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០០៩ (ឯកសារ [illegible])។



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C • C E T C

ចំណាត់ថ្នាក់ទៅលើឯកសារទាំងនោះនៅក្នុងសំណុំរឿង និងនៅក្នុងឯកសារ E16.1 ក៏ដោយ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ពុំមានឯកសារណាមួយក្នុងចំណោមឯកសារទាំងប្រាំបួននេះ មានខ្លឹមសារជា "ចម្លើយរបស់ជនសង្ស័យ" ដូចដែលមេធាវីការពារក្តីយល់ឃើញនោះទេ។ ទោះជាបែបនេះក្តី ឯកសារមួយក្នុងចំណោមឯកសារទាំងនេះ ត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះរួចទៅហើយ[១៣] ខណៈពេលដែលឯកសារបីផ្សេងទៀតមិនមានភាពពាក់ព័ន្ធ មានភាពច្រំដែល ឬមិនបានកំណត់បង្ហាញអត្តសញ្ញាណឱ្យបានត្រឹមត្រូវទេនោះ ហេតុនេះហើយសំណើសុំឱ្យមានការទទួលយកឯកសារទាំងនោះត្រូវបានបដិសេធចោល[១៤]។ ពាក់ព័ន្ធទៅនឹងឯកសារជម្លោះប្រដាប់អាវុធផ្សេងទៀតដែលមាននៅក្នុងឯកសារ E61.1 អង្គជំនុំជម្រះយល់ឃើញថា ឯកសារទាំងនេះមានភាពពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធីសវនាការ និងបានយល់ព្រមតាមសំណើសុំរបស់សហព្រះ រាជអាជ្ញា។

៧. ឯកសារ E152.1 ជាតារាង និយាយអំពីចម្លើយផ្សេងៗដែលបានផ្តល់ឱ្យដោយជនជាប់ចោទ នៅក្នុងដំណាក់កាលស៊ើបសួរ ព្រមទាំងឯកសារពាក់ព័ន្ធនានា ("ចម្លើយរបស់ជនជាប់ចោទ")[១៥]។ ឯកសារ E152.2 ជាតារាង ផ្ទុកនូវឯកសារយោងលើចម្លើយចំនួន ៦៩ ដែលបានផ្តល់ឱ្យដោយសាក្សីផ្សេងៗ ដែលត្រូវបានសួរយកចម្លើយនៅក្នុងដំណាក់កាលស៊ើបសួរ ("ចម្លើយរបស់ សាក្សី")[១៦]។ ចម្លើយទាំងអស់លើកលែងតែចម្លើយមួយប៉ុណ្ណោះ គឺជាផ្នែកមួយនៃសំណុំរឿង រីឯការប្រើប្រាស់ចម្លើយទាំងនេះធ្វើជាភស្តុតាង

---

[១៣] "សារទូរលេខចុះថ្ងៃទី៣ ខែមករា ឆ្នាំ១៩៧៩ របស់ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស នៃកម្ពុជាប្រជាធិបតេយ្យ ផ្ញើជូនប្រធានក្រុមប្រឹក្សាសន្តិសុខ ចុះថ្ងៃទី៣ ខែមករា ឆ្នាំ១៩៧៩" (ឯកសារ D60, ឧបសម្ព័ន្ធ ៣៧៤ ត្រូវបានចុះលេខថ្មីជា E3/209)។

[១៤] "ព័ត៌មានផ្សាយក្នុងក្រុងភ្នំពេញ ដោយសម្តេចកម្ពុជាប្រជាធិបតេយ្យ លេខ ០១៥" (ឯកសារ 20.29 ពីសេចក្តីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ)។ "អគ្គរដ្ឋទូតចិនផ្តល់បដិសណ្ឋារកិច្ចចំពោះ នួន ជា" និង "ទស្សនកិច្ចមកកាន់កម្ពុជាដោយគណៈប្រតិភូមិត្តភាពជប៉ុន" (ឯកសារ D60 ឧបសម្ព័ន្ធ៣០៥)។ និង "សេចក្តីថ្លែងការណ៍ថ្នាក់ជាតិជាសាធារណៈដោយលោក ខៀវ សំផន" (ឯកសារ D60 ឧបសម្ព័ន្ធ២៤៣)។ អង្គជំនុំជម្រះក៏បានកត់សម្គាល់ថា ឯកសារនេះមានការបកប្រែជាភាសាខ្មែរដោយផ្នែកតែប៉ុណ្ណោះ។

[១៥] "ឧបសម្ព័ន្ធ ក៖ ចម្លើយរបស់ជនជាប់ចោទ និងឯកសារភ្ជាប់" (ឯកសារ E152.1)។ សូមមើលផងដែរ "សំណើរបស់សហព្រះរាជអាជ្ញា សុំដាក់បញ្ចូលកំណត់ហេតុសក្ខីកម្ម និងឯកសារមន្ទីរស-២១ ដែលមានចំណារពាក់ព័ន្ធ ដែលប្រមូលបាននៅក្នុងអម្លុងពេលនៃកិច្ចស៊ើបសួរ" ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៩ (ឯកសារ E152)។

[១៦] "ឧបសម្ព័ន្ធ ខ៖ ការស្តាប់ចម្លើយសាក្សី" ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៩ (ឯកសារ E152.2)។



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C B E T C

មិនត្រូវបានជំទាស់ពីមេធាវីការពារក្តីនោះទេ[១៧]។ ចម្លើយមួយចំនួនក្នុងចំណោមចម្លើយទាំងនេះ ឬផ្នែកខ្លះក្នុងចំណោមនោះ ត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះរួចទៅហើយ និងត្រូវបានយោងម្តងហើយម្តងទៀតនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការ[១៨]។ ដោយមានអញ្ញត្រកម្មចំពោះចម្លើយដែលបានយោងនៅត្រង់លេខ ២៥[១៩] នៃឯកសារ E152.1 ដែលមិនមែនជាផ្នែកមួយនៃសំណុំរឿង អង្គជំនុំជម្រះយល់ឃើញថា ចម្លើយរបស់ជនជាប់ចោទទាំងអស់ និងឯកសារពាក់ព័ន្ធនានា (ដែលផ្អែកលើឯកសារនោះជនជាប់ចោទបានបញ្ចេញយោបល់នៅក្នុងដំណាក់កាលស៊ើបសួរ) ក៏ដូចជាចម្លើយរបស់សាក្សីទាំងអស់ មានភាពពាក់ព័ន្ធទៅនឹងកិច្ចដំណើរការនីតិវិធី។ អង្គជំនុំជម្រះសាលាដំបូងយល់ព្រមតាមសំណើសុំរបស់សហព្រះរាជអាជ្ញា។ នៅពេលដែលមានតែផ្នែកខ្លះនៃចម្លើយទាំងអស់នេះ ប៉ុណ្ណោះដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះកាលពីលើកមុននោះ ពេលនេះចម្លើយទាំងមូលត្រូវបានដាក់ចូលជាភស្តុតាង។

៨. ឯកសារ E152.3 ជាតារាង ផ្ទុកនូវឯកសារយោងលើឯកសាររបស់មន្ទីរសន្តិសុខ ស-២១ ចំនួន ៦០ ដែលមានចំណារដែលធ្វើដោយជនជាប់ចោទ។ មេធាវីការពារក្តីជំទាស់ទៅនឹងការដាក់ឯកសារទាំងអស់នេះនៅចំពោះមុខអង្គជំនុំជម្រះដោយហេតុថា ឯកសារទាំងនោះមិនបានឆ្លងកាត់ការពិភាក្សាតទល់គ្នានោះទេ និងថា សំណៅជាភាសាអង់គ្លេស និងជាភាសាបារាំង មិនស៊ីសង្វាក់គ្នាទេ។ ឯកសារសរុបចំនួន ១៤ឯកសារ ក្នុងចំណោមឯកសារទាំងអស់នេះ ឬផ្នែកខ្លះក្នុងចំណោមនោះ ត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះកាល

---

[១៧] មេធាវីការពារក្តីបានបង្ហាញថា វាមិនប្រកែកនឹងការប្រើ "ឯកសារទាំងអស់ដែលបានលើកឡើងដោយជនជាប់ចោទតាមសំណើរបស់សហចៅក្រមស៊ើបអង្កេត" មិនថាវាជាឧបសម្ព័ន្ធទៅនឹងចម្លើយរបស់ជនជាប់ចោទ ឬផ្តល់ជូននៅពេលក្រោយដោយជនជាប់ចោទនោះទេ។ ប្រតិចារឹកចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៩ ទំព័រ៧១។

[១៨] ទាំងនេះរួមមានឯកសារ D48/1 គឺ "កំណត់ហេតុនៃការចុះធ្វើការស៊ើបអង្កេតដល់ទីកន្លែងកើតហេតុ នៅជើងឯក" ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៩ ដែលត្រូវបានលប់ដោយភាន់ច្រឡំពីឯកសារ E152.1។

[១៩] យោងតាមមេធាវីការពារក្តី ឯកសារនេះគឺជារបាយការណ៍មួយដែលទាក់ទងនឹងសំណុំរឿងលេខ ០០២ (ប្រតិចារឹកចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៩ ទំព័រ៧១)។ ឯកសារនេះមិនមានក្នុងសំណុំរឿង ហើយដូច្នេះវានឹងមិនត្រូវបាន[illegible] ដោយអង្គជំនុំជម្រះទេ។

ពីលើកមុន ហើយឯកសារទាំងនោះត្រូវឆ្លងកាត់ការដេញដោលនៅក្នុងពេលសវនាការ[២០]។ នៅពេលដែលមានតែផ្នែកខ្លះនៃចម្លើយទាំងអស់នេះប៉ុណ្ណោះ ដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះកាលពីលើកមុននោះ ពេលនេះ ចម្លើយទាំងមូលត្រូវបានរួមបញ្ចូលជាភស្តុតាង។ ឯកសារដែលពាក់ព័ន្ធទាំងអស់នេះមានកំណត់ត្រឹមតែអង្គហេតុដែលថា ឯកសារទាំងនោះត្រូវបានបង្កើតឡើង និងក្នុងករណីដែលសមស្របធ្វើជាភស្តុតាងបង្ហាញថា ឯកសារទាំងនោះត្រូវបានធ្វើឡើងដោយសារការធ្វើទារុណកម្ម។ ឯកសារទាំងនោះ គឺមិនត្រូវបានអនុញ្ញាតអោយមកប្រើដើម្បីបញ្ជាក់ការពិតនោះទេ[២១]។

៩. ពាក់ព័ន្ធនឹងឯកសារដែលនៅសល់ចំនួន ៥៦ឯកសារទៀត អង្គជំនុំជម្រះរកឃើញថា ឯកសារទាំងនេះមានភាពស្រដៀងគ្នាទៅនឹងឯកសារដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ

---

[២០] "ចម្លើយសារភាពរបស់មន្ទីរសន្តិសុខ ស-២១ របស់ ACHAR KANG" (ឯកសារ E5/2.21) "ចម្លើយសារភាពរបស់មន្ទីរសន្តិសុខ ស-២១ របស់ SMANN Sless" (ឯកសារ E5/2.2) "ភស្តុតាងដែលអាចប្រឆាំងនឹង ឌុច" ជាពិសេស "ការបញ្ជារឲ្យធ្វើទារុណកម្មលើអ្នកទោសឈ្មោះ មុត ហេង Mot Heng របស់ ឌុច" និង "បញ្ជីឈ្មោះអ្នកទោសមន្ទីរសន្តិសុខ ស-២១" (ឯកសារ IS 18.81 បង់លេខថ្មី E3/367) "ការសួរចម្លើយរបស់ ឈ្មោះ សួន សាន SUAN San" (ឯកសារ E5/2.34) "ចម្លើយសារភាពរបស់ឈ្មោះ កែ គីមហួត KE Kim Huot" (ឯកសារ IS 5.35 បង់លេខថ្មី E3/369) ចម្លើយសារភាពរបស់ឈ្មោះ ស ផុន SAR Phon (ឬ SMANN Sless)" (ឯកសារ E5/2.1) "បញ្ជីឈ្មោះអ្នកទោសមន្ទីរសន្តិសុខ ស-២១ [ការប្រហារជីវិត]" (ឯកសារ D57-ឧបសម្ព័ន្ធ ០០២៨៦ បង់លេខថ្មី E3/371) "ចម្លើយសារភាពរបស់មន្ទីរសន្តិសុខ ស-២១ របស់ឈ្មោះ គឹម សុខ KIM Sok" (ឯកសារ E5/2.52) "ចម្លើយសារភាពរបស់មន្ទីរសន្តិសុខ ស-២១របស់ឈ្មោះ ប៊ុន ណារ៉ាក់ BUNN Narak" (ឯកសារ E5/2.9) "ចម្លើយសារភាពរបស់មន្ទីរសន្តិសុខ ស-២១ របស់ឈ្មោះ ឈាវ ស៊ុនហេង CHHEAV Sun Heng" (ឯកសារ E5/2.8) "ចម្លើយសារភាពរបស់មន្ទីរសន្តិសុខ ស-២១ របស់ឈ្មោះ ព្រុំ សំនៀង PRUM Samneang" (ឯកសារ E5/2.3) "ចម្លើយសារភាពរបស់មន្ទីរសន្តិសុខ ស-២១របស់ឈ្មោះ រុណ សាវី ROUN Savy" (ឯកសារ E5/2.5) "ឈ្មោះសមាជិកគ្រួសាររបស់ សុខ និង ម៉ៃ លន់ Mail Lun ដែលត្រូវគេបំផ្លាញ" (ឯកសារ IS 18.31 បង់លេខថ្មី E3/383) "លិខិតរបស់មន្ទីរសន្តិសុខ ស-២១ ផ្ញើពី ឌុច ជូនទៅ ប៊ុន" (ឯកសារ IS 18.15 បង់លេខថ្មី E3/376)។

[២១] ពាក់ព័ន្ធនឹងបញ្ហានេះដែរ អង្គជំនុំជម្រះគូសបញ្ជាក់បទបញ្ញត្តិនៃមាត្រា១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម: "រដ្ឋជាភាគីនីមួយៗ ត្រូវធានាថា ចម្លើយទាំងឡាយណាដែលបានធ្វើឡើងដោយសារតែការធ្វើទារុណកម្ម មិនអាចយោងធ្វើជាភស្តុតាងនៅក្នុងកិច្ចដំណើរការនីតិវិធីណាមួយឡើយ លើកលែងតែយោងដើម្បីប្រឆាំងនឹងជនដែលត្រូវចោទប្រកាន់ពីបទធ្វើទារុណកម្ម ធ្វើជាភស្តុតាងដែលបង្ហាញថាចម្លើយនោះត្រូវបានធ្វើឡើង"។



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C E T C

សាលាដំបូងរួចហើយ។ អង្គជំនុំជម្រះរកឃើញថា ឯកសារចំនួន ៤៦ នេះ គឺមិនមានភាពពាក់ព័ន្ធ ឬច្រំដែល។ ហេតុនេះ សំណើសុំនេះត្រូវបានបដិសេធចោល។

១០. ឯកសារ E160.1 គឺជាសៀវភៅដែលមានចំណងជើងថា "ពេជ្ឈឃាតបាត់ខ្លួន" ដែលនិពន្ធដោយ **Nic DUNLOP**[២២]។ មេធាវីការពារក្ដីមិនបានជំទាស់ទៅនឹងការដាក់សៀវភៅនេះនៅចំពោះមុខអង្គជំនុំជម្រះនោះទេ។ ព្រឹត្តិការណ៍នានាដែលបានរៀបរាប់នៅក្នុងសៀវភៅនេះត្រូវបានយកធ្វើជាសំអាងនៅក្នុងពេលសវនាការពីសំណាក់ជនជាប់ចោទផងដែរ ប៉ុន្តែសៀវភៅនេះមិនត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះជាផ្លូវការនោះទេ។ លើសពីនេះទៀត លោក DUNLOP ជាដំបូងត្រូវបានដាក់បញ្ចូលទៅក្នុងបញ្ជីឈ្មោះសាក្សីដែរ ប៉ុន្តែក្រោយមកត្រូវបានអង្គជំនុំជម្រះដកចេញវិញ[២៣]។ អង្គជំនុំជម្រះយល់ឃើញថា សៀវភៅនេះជាប់ពាក់ព័ន្ធនឹងសវនាការ និងបានយល់ព្រមតាមសំណើសុំរបស់សហព្រះរាជអាជ្ញា។

## គ. សម្ភារៈដែលបានស្នើសុំដោយមេធាវីការពារក្ដី

១១. ឯកសារ D80/1 គឺជាសៀវភៅដែលមានចំណងជើងថា "ប៉ុល ពត: កាយវិភាគសាស្ត្រនៃសុបិន្តអាក្រក់" ដែលនិពន្ធដោយ **Philip SHORT**[២៤]។ ឯកសារ D80/6 គឺជាសៀវភៅដែលមានចំណងជើងថា "ប្រទេសកម្ពុជាឆ្នាំសូន្យ" ដែលនិពន្ធដោយ **François PONCHAUD**[២៥]។ នៅពេលក្លាយជាផ្នែកមួយនៃសំណុំរឿងចាប់តាំងពីដំណាក់កាល

[២២] "ពេជ្ឈឃាដដែលបាត់ខ្លួន - រឿងរ៉ាវពីរបបខ្មែរក្រហម" របស់លោក Nic Dunlop Bloomsbury ឆ្នាំ២០០៥ (ឯកសារ ១៦០.១)។ *សូមមើលផងដែរ* "សេចក្ដីជូនដំណឹងរបស់សហព្រះរាជអាជ្ញាដើម្បីដាក់សៀវភៅរបស់លោក Nic Dunlop ដែលមានចំណងជើងថា "ពេជ្ឈឃាដដែលបាត់ខ្លួន" ទៅក្នុងសំណុំរឿង និងដើម្បីឱ្យទទួលយកធ្វើជាភស្តុតាងសម្រាប់សវនាការ" ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៩ (ឯកសារ E160)។

[២៣] ប្រតិចារឹកចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៩ ទំព័រ៦។

[២៤] "ប៉ុល ពត: កាយវិភាគសាស្ត្រនៃសុបិន្តអាក្រក់" ដោយ Philip Short, Denoel ឆ្នាំ២០០៧ ("ឯកសារ D80/1")។ សូមមើលផងដែរ "សំណើសុំដាក់ឯកសារទាំងឡាយទៅក្នុងសំណុំរឿង" ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០០៨ ("ឯកសារ D80")។

[២៥] "ប្រទេសកម្ពុជា ឆ្នាំសូន្យ" ដោយ Francois Ponchaud, Kailash ឆ្នាំ២០០១ ("ឯកសារ D80/6")។

ស៊ើបសួរមក សៀវភៅទាំងអស់នេះមិនដែលត្រូវបានយកមកធ្វើជាសំអាងនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការនោះទេ[២៦]។ ឥឡូវនេះ មេធាវីការពារក្ដីស្នើសុំដាក់សៀវភៅទាំងនេះនៅចំពោះមុខអង្គជំនុំជម្រះ។

១២. បន្ថែមលើនេះ មេធាវីការពារក្ដី ក៏បានស្នើសុំឱ្យដាក់សម្ភារៈខាងក្រោមនេះនៅចំពោះមុខអង្គជំនុំជម្រះផងដែរ ៖ ក) សៀវភៅមួយដែលមានចំណងជើងថា "The Two Worlds of Albert Speer" និពន្ធដោយលោក Henry T. KING[២៧]។ ខ) សាលក្រម និងសម្ភារៈដទៃទៀតនៃសំណុំរឿង *Obrenovic* នៅចំពោះមុខតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (ICTY)[២៨]។ គ) សៀវភៅដែលមានចំណងជើងថា "God Has a Dream - A Vision of Hope for Our Time" និពន្ធដោយ Archbishop Desmond TUTU[២៩] និងលិខិតមួយច្បាប់របស់លោក Henry T. KING[៣០]។

---

២៦ ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ ជុំ ស៊ីរ៉ាត់ Chum Sirath បានលើកឡើងថា បានជួបលោក Ponchaud ម្ដង (ប្រតិចារឹកចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៩ ទំព័រ៣៨)។

២៧ "ពិភពលោកពីររបស់ Albert Speer - ការត្រិះរិះរបស់រដ្ឋអាជ្ញានូរ៉ាំប៊ើក" Albert T. King ជាមួយនឹង Bettina Elles, ពត៌មានសកលវិទ្យាល័យអាមេរិក ឆ្នាំ១៩៩៥។ សេចក្ដីដកស្រង់ពីសៀវភៅនេះត្រូវបានដាក់ចូលក្នុងសំណុំរឿង សូមមើល ឯកសារ E5/9.1។

២៨ រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Dragan Obrenovic សាលក្រមផ្ដន្ទាទោស អង្គជំនុំជម្រះសាលាដំបូងតុលាការ ICTY សំណុំរឿងលេខ IT02/60/2 ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០៣។ សេចក្ដីដកស្រង់ពីប្រតិចារឹកនានា និងការថតវីដេអូអំពីកិច្ចដំណើរការនីតិវិធីសវនាការនៅក្នុងរឿងក្ដីនេះ ត្រូវបានដាក់ចូលក្នុងសំណុំរឿង។ សូមមើល ឯកសារ E5/9.3 និង E5/9.4។

២៩ "ព្រះជាម្ចាស់មានក្ដីសុបិន្ត - ទស្សនៈនៃក្ដីសង្ឃឹមសម្រាប់ពេលវេលារបស់យើង" ដោយ Desmond Tutu, Rider ឆ្នាំ២០០៥ (ឯកសារ E5/9.6)។

៣០ "សេចក្ដីថ្លែងរបស់លោក Herry T. King" ចុះថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០០៩ (ឯកសារ E5/9/2)។ លោក King ជាដំបូងត្រូវបានបញ្ចូលទៅក្នុងបញ្ជីឈ្មោះអ្នកជំនាញ ប៉ុន្ដែបានស្លាប់មុនពេលឡើងនិយាយ។ លិខិតត្រូវបានដាក់បន្ទាប់មកទៀត និងគូសបញ្ជាក់ពីមតិយោបល់របស់លោក King ទៅលើការផ្ដន្ទាទោសទៅលើលោក Albert Speer ដោយតុលាការយោធានូរ៉ាំប៊ើក។ លោក King ត្រូវបានស្នើឱ្យផ្ដល់សក្ខីកម្មផ្ទាល់មាត់ទៅលើការកាត់សេចក្ដីលើលោក Albert Speer ដែលជាជនជាប់ចោទតែម្នាក់គត់ដើម្បីទទួលខុសត្រូវនៅចំពោះមុខតុលាការយោធាអន្តរជាតិនូរ៉ាំប៊ើក សាលក្រមបានចេញនៅក្នុងរឿងក្ដីនេះ និងនៅក្នុងជីវិតរបស់គាត់បន្ទាប់ពីការផ្ដន្ទាទោស។ សូមមើល សេចក្ដីសម្រេចអំពីការកិច្ចរបស់អ្នកជំនាញ ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៩ (ឯកសារ E51)។

១៣. អង្គជំនុំជម្រះយល់ឃើញថា សៀវភៅ និងសាលក្រមនៃតុលាការផ្សេងទៀតទាំងនេះមិនបានបង្កើតជាភស្តុតាងតាមស្មារតីនៃវិធាន ៨៧(២) ឡើយ។ ដោយជាឯកសារដែលអាចអាចយកមកប្រើប្រាស់បានជាទូទៅនោះ ជាធម្មតាមិនមានការហាមឃាត់ក្នុងការយោងទៅរកឯកសារទាំងនោះដើម្បីគាំទ្រនូវសេចក្ដីសន្និដ្ឋានផ្លូវច្បាប់របស់ខ្លួននោះទេ។ នៅពេលដែលសហព្រះរាជអាជ្ញាមិនបានជំទាស់ទៅនឹងលិខិតរបស់លោក King ដែលត្រូវបានដាក់បញ្ចូលជាភស្តុតាងនោះ អង្គជំនុំជម្រះយល់ឃើញថា លិខិតនោះបញ្ជាក់ពីទស្សនៈផ្ទាល់របស់លោក King អំពីទម្ងន់ចំពោះការទទួលសារភាពអំពីការទទួលខុសត្រូវរបស់ Albert Speer ដែល សម្រេចដោយតុលាការនូរ៉ាំប៊ើក។ លិខិតនោះ និយាយតែពីលោក Albert Speer ហើយមិនមានការប្រៀបធៀបដោយផ្ទាល់អំពីរូបគាត់ជាមួយនឹងការជំនុំជម្រះក្ដីនៅទីនេះទេ។ ភស្តុតាងដ៏គ្រប់គ្រាន់ដទៃទៀតស្ដីអំពីឥទ្ធិពលនៃការទទួលសារភាពអំពីការទទួលខុសត្រូវរបស់ជនជាប់ចោទត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះរួចហើយ។ ដូច្នេះ សំណើសុំរបស់មេធាវីការពារក្ដីទាំងនេះ ត្រូវបដិសេធចោល។

## ឃ. សម្ភារៈដែលបានស្នើដោយមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្រុម២

១៤. នៅក្នុងឯកសារ E2/32/5 មានសេចក្ដីសន្និដ្ឋានរបស់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្រុម២ ដែលបានលើកឡើងនៅក្នុងតុលាការជាសាធារណៈ ស្ដីអំពីការចាប់រំលោភលោកស្រី ណាំ ម៉ុន (Nam Mon) ដែលជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលត្រូវបានចោទប្រកាន់[៣១]។ មេធាវីការពារក្ដីជំទាស់ទៅនឹងសំណើនេះ ដោយសំអាងមូលហេតុថា សំណើនេះយោងទៅលើអង្គហេតុថ្មី ដែលមិននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ការចោទប្រកាន់ទាំងនេះត្រូវបានលើកឡើងនៅដំណាក់កាលយឺតពេលហើយក្នុងដំណើរការនីតិវិធី បន្ទាប់ពីការស្ដាប់ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ណាំ ម៉ុន នៅក្នុងតុលាការរួចមក។ អនុលោមតាមវិធានផ្ទៃក្នុង ៨៧(៤)

---

[៣១] "សំណើសុំដាក់ចម្លើយបន្ថែមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី E2/32 នៃសំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អសជ" ចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០០៩ (ឯកសារ E2/32/5)។ ឯកសារ E2/32/4 គឺជាចម្លើយបន្ថែមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ណាំ ម៉ុន Nam Mon ក៏ពាក់ព័ន្ធនឹងការចោទប្រកាន់ដូចគ្នានោះដែរ។



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE
E C C C

អង្គជំនុំជម្រះយល់ឃើញថា ការចោទប្រកាន់ទាំងនេះគឺយឺតពេលហើយ។ លើសពីនេះទៀត ភស្តុតាងដែលពាក់ព័ន្ធមិនអាចទទួលបាននៅក្នុងរយៈពេលដ៏សមស្របមួយបានឡើយ។ ដូច្នេះ សំណើនេះ ត្រូវបានបដិសេធចោល។

## ង. សម្ភារៈទាក់ទិនទៅនឹងដើមបណ្តឹងរដ្ឋប្បវេណី

១៥. ឯកសារ E139, E161 និង E164 មានសម្ភារៈនានានៅក្នុងឧបសម្ព័ន្ធនៃឯកសារទាំងនេះ ស្តីអំពីដើមបណ្តឹងរដ្ឋប្បវេណីជាច្រើន ដែលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ខ្លួន ត្រូវបានតវ៉ាដោយមេធាវីការពារក្តី[៣២]។ មេធាវីការពារក្តីមិនជំទាស់ទៅនឹងសម្ភារៈទាំងនេះ ដែលត្រូវបានដាក់ជាភស្តុតាងឡើយ។ សូមរំលឹកថា បន្ទាប់ពីការលើកទឡ្ហីករណ៍ តទល់គ្នាយ៉ាងយូរក្នុងអំឡុងពេលសវនាការ អង្គជំនុំជម្រះបានបង្គាប់ឲ្យដើមបណ្តឹងរដ្ឋប្បវេណីដែលឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ខ្លួនត្រូវបានជំទាស់ពីលើកមុន ដាក់ សម្ភារៈជាភស្តុតាង បន្ថែមណាក៏ដោយដែលអាចបង្កើតជាទំនាក់ទំនងរបស់ពួកគេទៅនឹង ជនរងគ្រោះនៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០១ នៅក្នុងរយៈ-ពេលកំណត់មួយ[៣៣]។ ការដាក់សម្ភារៈបែបនេះ គឺជាប់ពាក់ព័ន្ធគ្នា និងមានប្រយោជន៍ដល់ ការស្វែងរកការពិត។ ដូច្នេះ សំណើសុំនេះត្រូវបានអនុញ្ញាត។

១៦. ហេតុផលដូចគ្នានេះដែរ អង្គជំនុំជម្រះសាលាដំបូងពិចារណាឃើញថា សម្ភារៈជាភស្តុតាងបន្ថែមទៀតពាក់ព័ន្ធនឹងដើមបណ្តឹងរដ្ឋប្បវេណី ដែលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានជជែកតវ៉ាពីមេធាវីការពារក្តី និងត្រូវបានដាក់ដោយក្រុមដើមបណ្តឹងរដ្ឋប្ប

---

[៣២] សូមមើលសម្ភារៈដែលបានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងឯកសារនានាខាងក្រោម: "ឯកសារថ្មីៗពាក់ព័ន្ធនឹងដើមបណ្តឹងរដ្ឋប្បវេណី D25/11, E2/39, E2/81 និង E2/84" ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ("ឯកសារ E139")។ « ឯកសារថ្មីពាក់ព័ន្ធនឹងដើមបណ្តឹងរដ្ឋប្បវេណី E2/30, E2/34, E2/63, E2/70, E2/71, E2/72, E2/78, E2/79 et E2/81 », ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៩ ("ឯកសារ E161"); « ឯកសារថ្មីពាក់ព័ន្ធនឹងដើមបណ្តឹងរដ្ឋប្បវេណី E2/30, E2/38 et E2/76 », ចុះថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០០៩ (ឯកសារ E164).

[៣៣] ប្រតិចារឹក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ ទំព័រ ៤។

វេណីផ្សេងទៀត ក៏ត្រូវបានរួមបញ្ចូលជាភស្តុតាងផងដែរ[៣៤]។ ដោយសារតែសម្ភារៈនេះ មិនទាន់ត្រូវបានដេញដោលនៅក្នុងតុលាការនោះ មេធាវីការពារក្តីអាចដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរពាក់ព័ន្ធទៅនឹងសម្ភារៈនេះបាន។

១៧. អង្គជំនុំជម្រះសាលាដំបូងបានពិចារណាឃើញថែមទៀតថា ដោយមានអញ្ញត្រកម្មលើឯកសារ E2/32/4 និង E2/32/5 ដែលបានលើកឡើងនៅក្នុងកថាខណ្ឌទី១២ ខាងលើ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងឯកសារភ្ជាប់ដែលពាក់ព័ន្ធនានារបស់ដើមបណ្តឹងដែល បានឡើងនិយាយក្នុងនាមជាអ្នកនៅរស់រានមានជីវិតដែលបានលើកឡើង ក៏ជាអ្នកដែលបានដកសំណើសុំឡើងនិយាយរបស់ខ្លួនផងដែរនោះ ត្រូវបានពិចារណាឃើញថាបានដាក់នៅចំពោះមុខអង្គជំនុំជម្រះផងដែរ[៣៥]។ អង្គជំនុំជម្រះរំលឹកថា មេធាវីការពារក្តីមានឱកាសក្នុងការបញ្ចេញយោបល់លើឯកសារទាំងនេះរួចទៅហើយ រួមទាំងនៅក្នុងបរិបទនៃវត្តមានរបស់ ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងតុលាការផងដែរ[៣៦] ឬនៅក្នុងកិច្ចពិភាក្សាតទល់គ្នាលើការជជែកតវ៉ាលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី[៣៧]។

## ហេតុដូច្នេះសម្រេច÷

**ទទួល** សំណើសុំដាក់សម្ភារៈនានាដូចខាងក្រោមនៅចំពោះមុខអង្គជំនុំជម្រះ៖

- ឯកសារ D99/1។

---

[៣៤] “សំណើសុំផ្តល់ភស្តុតាងក្នុងការគាំទ្រដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២: E2/22, E2/35, E2/64, និង E2/83” ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៩ (ឯកសារ E163/3)។ “សំណើសុំផ្តល់ភស្តុតាងក្នុងការគាំទ្រដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១ ចំនួនប្រាំនាក់” ចុះថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០០៩ (ឯកសារ E165) និងឯកសារនានាដែលបានភ្ជាប់ជាឧសម្ព័ន្ធជាមួយ។

[៣៥] សូមមើល ពាក្យសុំនិងឯកសារនានាដែលបានភ្ជាប់របស់ដើមបណ្តឹងរដ្ឋប្បវេណីដូចខាងក្រោម: លោក ជុំ ម៉ី (D25/3) លោក ប៊ូ ម៉េង (D25/1) លោក លី ហ៊័រ (E2/61) លោក ឡាយ ចាន់ (E2/23) លោក សោត ខន (E2/33) លោក ជិន ម៉េត (E2/80) អ្នកស្រី ណាំ ម៉ុន (E2/32) លោក ម៉ន សុធា (E2/82) អ្នកស្រី រស់ ម៉េន(D25/9) លោក ផាត គឹមឈុន(E2/81) លោក Jeffey James (E2/86) និងអ្នកស្រី គៀង វណ្ណារី(E2/77)។

[៣៦] ប្រតិចារឹក ចុះថ្ងៃទី៣០ ខែមិថុនា និងថ្ងៃទី១ ដល់១៣ ខែកក្កដា ឆ្នាំ២០០៩។

[៣៧] ប្រតិចារឹក ចុះថ្ងៃទី២៦ និងទី២៧ ខែសីហា ឆ្នាំ២០០៩។

00398392



- សម្ភារៈនានាដែលបានយោងនៅក្នុងឯកសារ E61.1 ដោយមានអញ្ញត្រកម្មលើឯកសារ 20.29 នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ, ឯកសារ D60 ឧបសម្ព័ន្ធ ៣០៥ និង ឯកសារ D60 ឧបសម្ព័ន្ធ ២៤៣។
- ចម្លើយនានាដែលបានយោងនៅក្នុងឯកសារ E152.1 រួមទាំងឯកសារទាំងអស់ដែលជនជាប់ចោទបានបញ្ចេញយោបល់នៅក្នុងដំណាក់កាលស៊ើបសួរ និងដោយមានអញ្ញត្រកម្មលើឯកសារដែលបានយោងនៅត្រង់លេខ ២៥ នៃឯកសារ E152.1។
- ចម្លើយនានាដែលបានយោងនៅក្នុងឯកសារ E152.2។
- ឯកសារទាំងអស់នោះដែលបានយោងនៅក្នុងឯកសារ E152.3 ដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះរួចទៅហើយ។
- ឯកសារ E160.1។
- សម្ភារៈនានាដែលបានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងឯកសារ E139, E161 និងE164។

នៅពេលដែលមានតែផ្នែកខ្លះនៃសម្ភារៈទាំងអស់នេះត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះកាលពីលើកមុន ពេលនេះ សម្ភារៈទាំងមូលត្រូវបានរួមបញ្ចូលទៅក្នុងភស្តុតាង។

**បដិសេធ** សំណើសុំទាំងអស់ដែលនៅសល់។

យោងតាមហេតុផលរបស់អង្គជំនុំជម្រះ អង្គជំនុំជម្រះ **ពិចារណាឃើញថា** សម្ភារៈដែលបានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹង ឯកសារ E163/3 និង E165 ត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ហើយជាលទ្ធផល **បង្គាប់ឱ្យ** មេធាវីការពារក្តីដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរពាក់ព័ន្ធនឹងសម្ភារៈទាំងអស់នេះ នៅក្នុងរយៈពេល៧ថ្ងៃគិតចាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីសម្រេចនេះ។

យោងតាមហេតុផលរបស់អង្គជំនុំជម្រះ អង្គជំនុំជម្រះ **ពិចារណាឃើញថា** ដោយមានអញ្ញត្រកម្មលើឯកសារ E2/32/4 E2/32/5 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងឯកសារនានាដែលបានភ្ជាប់ទៅនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលបានឡើងធ្វើសេចក្តីថ្លែងក្នុងនាមជាអ្នករស់រានមានជីវិត ក៏ដូចជាអ្នកដែលបានដកសំណើសុំឡើងធ្វើសេចក្តីថ្លែងរបស់ខ្លួនផងដែរនោះ ត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ។



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C • C E T C

E176

តារាងដែលបានកំណត់អត្តសញ្ញាណយ៉ាងច្បាស់លាស់អំពីសម្ភារៈ ដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះបន្ទាប់ពីសេចក្តីសម្រេចនេះ នឹងចេញតាមពេលកំណត់។ តារាងនេះក៏នឹងបង្ហាញផងដែរ អំពីសម្ភារៈណាដែលត្រូវដាក់ចូលក្នុងឯកសារ E3 នៃសំណុំរឿង ។

ភ្នំពេញ ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៩

ប្រធានអង្គជំនុំជម្រះសាលាដំបូង

និល - ណុន